# ជីវិតនៅក្នុងដី ជីវិតរបស់ដំណាំស្រូវ និងជីវិតរបស់កសិករ

យើងខ្ញុំសង្កេតឃើញថា កសិករយើងកំពុងជួបបញ្ហានៃការធ្លាក់ចុះនៃទិន្នផលស្រូវ ឬ ការរក្សាបាននូវទិន្នផលតែត្រូវចំណាយកាន់តែច្រើនលើការប្រើប្រាស់ជីផ្សារ ។ មូលហេតុដ៏សំខាន់ដែលនាំមកនូវការធ្លាក់ចុះនូវទិន្នផល និងការកើននៃការចំណាយលើការប្រើប្រាស់ជីគីមី គឺជាការរិចរិលនៃសារធាតុមមោកនៅស្រទាប់ខាងលើរបស់ដី ការថយចុះនៃគុណភាពគ្រាប់ពូជស្រូវ និងទំលាប់ក្នុងការធ្វើស្រែដែលមិនសូវអំណោយផលដល់ស្រូវនិមួយៗ អាចលូតលាស់បានពេញលេញល្អទៅតាមសក្តានុពលធម្មជាតិ ។

នៅពេលនេះ យើងខ្ញុំសូមផ្តោតទៅលើបញ្ហាទាក់ទងទៅនឹងសារធាតុមមោក ។ ដើមឡើយដីស្រែសំបូរទៅដោយសារធាតុមមោក (ពពួកស្លឹកឈើ លាមកសត្វផ្សេងៗដែលពុកផុយរលួយល្អ មានពណ៌ក្រម៉ៅ ហើយស្ថិតនៅផ្នែកខាងលើនៃស្រទាប់ដី) ជាពិសេសដីដែលកើតចេញពីការកាប់ឆ្ការព្រៃធម្មជាតិ ។ ដីរបៀបនេះ ធ្វើឲ្យស្រូវមានការលូតលាស់បានល្អនៅឆ្នាំដំបូង ក៏ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឲ្យដីស្រទាប់លើដែលសំបូរដោយមមោកនេះមានការរិចរិលដោយសារកត្តាសំខាន់ៗមួយចំនួន ដូចជា ការហូររិចរិល និងហើរទៅកាន់បរិយាកាស ការស្រូបយកដោយស្រូវ ការភ្ជួរត្រឡប់ជារៀងរាល់ឆ្នាំរបស់កសិករ ការដុតចោលនូវជញ្ជ្រាំង និងការមិនបានយកជីធម្មជាតិ ឬ សារធាតុសរីរាង្គ (អង្កាម ចំបើង ស្លឹកឈើ លាមកសត្វ ។ល។) មកដាក់ចូលក្នុងដីវិញ ។ ដោយសារកត្តាខាងលើនេះ ដែលសុទ្ធសឹងជាទង្វើរបស់កសិករខ្លួនឯង ធ្វើឲ្យពីមួយឆ្នាំទៅមួយឆ្នាំ ដីកាន់តែខ្សោះជីជាតិ ទិន្នផលស្រូវត្រូវបានថយចុះ ។

ដើម្បីទប់នូវការថយចុះនៃទិន្នផលស្រូវ កសិករបានងាកទៅរកការទិញជីពីទីផ្សារយកមកដាក់បំប៉នបន្ថែម ។ ហើយដើម្បីបានប្រាក់មកទិញជី កសិករត្រូវការខ្ចីប្រាក់ពីគេ ។ ដើម្បីបានប្រាក់មកសងថ្លៃបំណុលជីកសិករត្រូវបង្ខំចិត្តលក់ស្រូវក្នុងតម្លៃថោកពេលរដូវប្រមូលផលកាត់ ហើយខ្ចីលុយគេបន្ថែម ដើម្បីទិញអង្ករនៅពេលរដូវដកស្ទូងដែលជាពេលអង្ករឡើងថ្លៃ ។ ដោយសារតែទង្វើទាំងនេះហើយជាបណ្តើរៗ ធ្វើឲ្យអ្នកស្រែធ្លាក់ចូលក្នុងអន្ទាក់ភាពក្រីក្រកាន់តែជ្រៅទៅៗ ។ ដើម្បីរំដោះខ្លួនចេញពីស្ថានភាពរបៀបនេះ ខ្ញុំយល់ថាកសិករត្រូវតែចាប់ផ្តើមកសាងឲ្យបានវិញនូវសារធាតុមមោកនៅស្រទាប់ដីខាងលើតាមរយៈការប្រមូលនូវជីធម្មជាតិការដាំដើមឈើយកស្លឹក ការដាំដីស្រស់តាមវាលស្រែ ការចាប់ផ្តើមធ្វើការភ្ជួរដោយមិនត្រឡប់លើផ្នែកខ្លះៗរបស់ស្រែជាបណ្តើរៗ ។ល។ តាមពិតវាមានជំរើសច្រើនដែលកសិករអាចធ្វើបាន ដើម្បីស្តារឡើងវិញនូវសារធាតុមមោកនៅស្រទាប់ដីខាងលើ ។ អ្វីដែលសំខាន់គឺកសិករត្រូវមានឆន្ទៈមោះមុតក្នុងការប្រើឲ្យបានច្រើននូវអ្វីដែលមាន ហើយធ្វើឲ្យបានច្រើននូវអ្វីដែលអាចធ្វើបាន ដើម្បីកសាងនូវសារធាតុមមោកដែលជាមូលដ្ឋានគ្រឹះនៃជីវិតនៅក្នុងដី ជីវិតរបស់ដំណាំស្រូវ និងជីវិតរបស់កសិករ ។

**បណ្ឌិត យ៉ង សាំងកុមារ**